ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមហាផ្ទៃ
សាលាខេត្តកោះកុង
លេខ : ០៣៥ ស ជ ណ

កោះកុង . ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០១១

## ជំរាបមក

## លោក អ៊ុង ធិរា ប្រធានអង្គការមរតក

**កម្មវត្ថុ :** ស្តីពីការចុះបញ្ជីរបស់អង្គការមរតក ដែលមានអាសយដ្ឋាន នៃទីស្នាក់ការកណ្តាលនៅផ្ទះលេខ ៤៣៧ ភូមិស្រែអំបិល ឃុំស្រែអំបិល ស្រុកស្រែអំបិល ខេត្តកោះកុង ។

**យោង** :-ចំណារយល់ព្រមរបស់រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១១ ស្តីពីការចុះបញ្ជី អង្គការមរតក នៅក្រសួងមហាផ្ទៃ។

- លិខិតលេខ ០០១ ចុះថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០១១ ស្តីពីការចុះបញ្ជី អង្គការមរតក។

តបតាមកម្មវត្ថុ និង យោងខាងលើខ្ញុំសូមជំរាបជូនលោកប្រធានអង្គការមរតក ឱ្យបានជ្រាបថា : អភិបាលនៃគណៈអភិបាលខេត្តកោះកុង បានទទួលរួចហើយនូវលិខិត ស្តីពីការចុះបញ្ជីរបស់អង្គការមរតក ដែលមានទីតាំងនៃទីស្នាក់ការកណ្តាលនៅផ្ទះលេខ ៤៣៧ ភូមិស្រែអំបិល ឃុំស្រែអំបិល ស្រុកស្រែអំបិល ខេត្តកោះកុង រួចហើយ ។ ក្នុងនាមអាជ្ញាធរខេត្ត ខ្ញុំសូមរំលឹកដល់ លោកប្រធានអង្គការមរតកត្រូវអនុវត្តន៍តាមលក្ខន្តិកៈ និង ធ្វើសកម្មភាពការងារ ក្នុងក្របខណ្ឌ័អង្គការអព្យាក្រឹត្យ មិនប្រកាន់ពូជសាសន៍ និន្នាការនយោបាយ មិនបំរើអោយគណបក្សនយោបាយណាមួយឡើយ ។ ដើម្បីអោយការងារព្រឹត្តទៅមានភាពល្អប្រសើរអង្គការរបស់លោកត្រូវ :

- សហការជាមួយអាជ្ញាធរមានសមត្ថកិច្ចនៅក្នុងពេលធ្វើសកម្មភាព
- នៅពេលធ្វើសកម្មភាពអង្គការត្រូវធ្វើសំណើមកអាជ្ញាធរខេត្តតាមឋានានុក្រមម្តងទៀតដោយបញ្ជាក់ពីសកម្មភាពរបស់ខ្លួន
- នៅពេលផ្លាស់ប្តូរទីតាំងរបស់អង្គការ ត្រូវធ្វើសេចក្តីជូនដំណឹង មកអាជ្ញាធរខេត្តតាមឋានានុក្រមសារជាថ្មី
- អង្គការត្រូវផ្តល់របាយការណ៍ អំពីសកម្មភាពការងារជូនខេត្តរៀងរាល់ខែ ត្រីមាស ឆមាស ឆ្នាំ ឱ្យបានទៀងទាត់ ។

អាស្រ័យហេតុនេះ សូមលោកប្រធានជ្រាប និងចាត់ចែងអនុវត្ត អោយមានប្រសិទ្ធិភាព ។

សូមលោកប្រធាន ទទួលនូវការរាប់អានដ៏ស្មោះអំពីខ្ញុំ ។

**ចំលងជូន**

-ក្រសួងមហាផ្ទៃ (ដើម្បីជូនជ្រាប)
-ស្នងការដ្ឋាននគរបាលខេត្ត
-សាលាស្រុកស្រែអំបិល
-ឯកសារ-កាលប្បវត្តិ

**អភិបាលខេត្ត** ។.

**ប៊ុន លើក**

**Kingdom of Cambodia**
**Nation Religion King**

**Ministry of Interior**
**Koh Kong provincial Hall**

No: 035 សជណ

Koh Kong, 19th April 2011

**To**

**Mr. Oung Tivea, Executive Director of MORODOK**

**Subject:** MORODOK Organization registered at Ministry of Interior as local NGO, office address: # 437, Sre Ambel village, Sre Ambel commune, Sre Ambel district of Koh Kong province.

**Reference**: - Approval Letter No. 495 សជណ, dated 4th April 2011 on registering of MORODOK organization as local NGO at Ministry of Interior (MoI).
- Application letter No. 001, dated 15 March 2011, requesting for registering of MORODOK Organization at Ministry of Interior as local NGO.

Response to the above subject and reference letters, I would like to inform you, Executive Director of MORODOK that the Governor of Koh Kong province received the approval letter from Ministry of Interior (MoI), No. 495 សជណ, dated 4th April 2011 on registering of MORODOK organization as local NGO, office address: # 437, Sre Ambel village, Sre Ambel commune, Sre Ambel district of Koh Kong province.

On behalf of provincial authority, I would alert you to oblige follow to the Constitution of MORODOK and implement activities under the framework as neutral local independent NGO, not discriminate on races and religion, not baring political tendency and not follow to any political organization and to be a political server.

In order the operation of your organization could be carried on smoothly, you must take actions follow the administrative procedure as following:

- Cooperate with local authority when implement your organization's activities.
- Present your NGO work plan to local authorities at various levels, district and province.
- When changing your organization's office location, you must report to authority at various levels.
- Your organization must regularly submit progress report (monthly, 3-mothly, 6 monthly and annually).

As above mention, I would like you to be aware and take actions effectively.

Sincerely yours.

Governor of Koh Kong

*Signature and stamp*

H.E. Boun Loeut

Copy confirm to:
- Ministry of Interior
- Koh Kong Provincial Police.
- Sre Ambel district admin
- History & Documentary

Unofficial translation version (for internal use only)